Minnesota Department of Health • ពត៌មានការពិតអំពីប្យ៉ូភេរវកម្ម 10/11/2005

# Viral Hemorrhagic Fevers (VHFs)

## តើអ្វីជាគ្រុនឈាម?

រោគគ្រុនឈាម ជាមេរោគ១ក្រុម បណ្តាលមកពីមេរោគផ្សេងៗជាច្រើន ជម្ងឺទាំងនេះមានអនុភាពជាច្រើន ទៅលើប្រព័ន្ធសរីរាង្គ នៅពេលជាមួយគ្នា។ វាធ្វើឲ្យខូចខាតសរសៃឈាម និងជ្រៀតជ្រែកនឹងលទ្ធិភាពខ្លួនប្រាណក្នុងការគ្រប់គ្រងឈាមខ្លួនឯង។



*មេរោគអ៊ីបូលា*

រោគគ្រុនឈាមខ្លះ វាស្រាលទេ ក៏ប៉ុន្តែរោគឯទៀត វាធ្ងន់ធ្ងរ។ រោគគ្រុនឈាមនេះ តែងតែបណ្តាលឲ្យចេញឈាម និងរោគសញ្ញាឯទៀត។ ការគ្រាន់តែចេញឈាម កម្រនឹងបណ្តាលឲ្យស្លាប់ណាស់។

មានរោគមួយចំនួននៃរោគគ្រុនឈាម ដែលអាចប្រើជាអាវុធ។ វារាប់ទាំង :

- មេរោគអ៊ីបូលា (Ebola)
- មេរោគម៉ាបឺក (Marburg)
- មេរោគឡាសា (Lassa)
- មេរោគភពថ្មី (New World arenaviruses)
- រោគគ្រុនឈាមម៉ាជូប៉ូ Machupo (Bolivian hemorrhagic fever)
- រោគគ្រុនឈាមជូនីន Junin (Argentine hemorrhagic fever)
- រោគគ្រុនឈាមកាណារីតូ Guanarito (Venezuelan hemorrhagic fever)
- រោគគ្រុនឈាមសាបៀ Sabia (Brazilian hemorrhagic fever)
- រោគគ្រុនឈាមរីវ (Rift Valley Fever)
- រោគគ្រុនឈាមលឿង Yellow Fever
- មេរោគគ្រុនឈាមព្រៃគីយ៉ាសានី (Kyasanur Forest)
- រោគគ្រុនឈាមអូម (Omsk hemorrhagic fever)

## តើអ្នកឆ្លងជម្ងឺទាំងនេះតាមរបៀបណា?

តាមធម្មតា មនុស្សឆ្លងរោគគ្រុនឈាមពីចៃ មូស រឺសត្វកណ្តុរ។ មនុស្សអាចឆ្លងរោគនេះ នៅពេលគេបានប៉ះពាល់ទឹកនោម លាមក និងវត្ថុធាតុពីសត្វកណ្តុរដែលមានរោគ។ មនុស្សអាចឆ្លងរោគគ្រុនឈាមផងដែរ ពីមូសខាំ រឺចៃខាំ រឺដោយសារញៀចចៃដែលមានរោគ។ ក្នុងករណីខ្លះ វាមិនច្បាស់ទេ ពីរបៀបដែលមនុស្សឆ្លងជម្ងឺនេះ។

## តើអាចឲ្យអ្នកឆ្លងជម្ងឺទាំងនេះពីមនុស្សឯទៀតបានរឺទេ?

បែបមេរោគគ្រុនឈាមខ្លះៗ រាប់បញ្ចូលទាំង អ៊ីបូលា ម៉ាបឺកនិងឡាសា។ មេរោគទាំងនេះ អាចឆ្លងរាលត្បាតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ វាឆ្លង តាមរយៈការទាក់ទងជិតស្និទពីមនុស្សដែលមានរោគ រឺទឹករាងកាយរបស់គេ។ មនុស្សក៏អាចឆ្លងតាមរយៈវត្ថុប្រឡាក់មេរោគ ដូចជាម្ជុល រឺម្ជុលចាក់ថ្នាំ។

## តើហេតុអ្វីបានជាគេគឹតថា ជម្ងឺទាំងនេះអាចយកមកប្រើជាអាវុធដ៏ឃោរឃៅបាន?

បែបមេរោគគ្រុនឈាមខ្លះៗ រាប់បញ្ចូលទាំង អ៊ីបូលា ម៉ាបឺក លីសា គ្រុនក្តៅលឿង និងមេរោគភពថ្មីខ្លះៗ អាចធ្វើជាវត្ថុរាវ។ បន្ទាប់មកអាចបញ្ចេញទៅក្នុងខ្យល់អាកាស ហើយប្រើចម្លងរោគដល់មនុស្ស។ ឯរោគគ្រុនឈាមឯទៀត រាប់ទាំងរោគគ្រុនក្តៅរីវាលី បណ្តាលឲ្យមានការឆ្លងនៅពេលបញ្ចេញទៅក្នុងខ្យល់អាកាសក្នុងមន្ទីពិសោធ។

សហភាពសូវៀតដើម បានបង្កើតឡើងនូវមេរោគម៉ាបឺកសំរាប់ប្រើជាអាវុធ និងដកពិសោធពីរោគអ៊ីបូលា ឡាសា រីវាលី រោគគ្រុនលឿងនិងភពថ្មី។ សហរដ្ឋបានដកពិសោធមេរោគទាំងអស់នេះ លើកលែងតែ រោគម៉ាបឺក និងអ៊ីបូលា។ គេបានជឿថា កូរ៉េខាងជើងបង្កើតឡើងមេរោគគ្រុនលឿងជាអាវុធ។

MINNESOTA MDH DEPARTMENT OF HEALTH
Communications Office
625 North Robert Street/Box 64975
St. Paul, MN 55164-0975
(651) 201-4989
www.health.state.mn.us

# Viral Hemorrhagic Fevers (VHFs) – ទំព័រទី 2

## តើអាចព្យាបាលជម្ងឺគ្រុនឈាមនេះបានរឺទេ?

ថ្នាំប្រឆាំងមេរោគ អាចយកមកប្រើបានដើម្បីព្យាបាលរោគគ្រុនក្តៅខ្លះៗ។ ការថែទាំនិងព្យាបាលរោគសញ្ញាទាំងនេះ មានសារៈសំខាន់សំរាប់ជម្ងឺទាំងនេះ។

## តើអាចការពារកុំឲ្យមានជម្ងឺទាំងនេះបានរឺទេ?

មានថ្នាំការពារសំរាប់រោគគ្រុនក្តៅខ្លះៗ រាប់ទាំងរោគគ្រុនក្តៅលឿងផង។ ការពិសោធថ្នាំការពារ កំពុងតែស្រាវជ្រាវរកសំរាប់រោគគ្រុនខ្លះៗ។ នៅផ្នែកដែលរោគមានកើតឡើងតាមធម្មជាតិ ការខិតខំប្រឹងប្រែងដើម្បីគ្រប់គ្រងមូសនិងចៃ ដែលនឹងអាចជួយការពារមិនឲ្យមានជម្ងឺគ្រុនក្តៅបែបខ្លះៗទៀត។

## តើគួរឲ្យខ្ញុំធ្វើអ្វី ប្រសិនបើគឹតថា ខ្ញុំប្រហែលបានឆ្លងជម្ងឺគ្រុនឈាមណាមួយហើយនោះ?

ប្រសិនបើអ្នកមានរោគគ្រុនឈាមបែបណាមួយប៉ះពាល់ វាមិនច្បាស់ថាអ្នកនឹងដឹងនោះទេ។ ក៏ប៉ុន្តែប្រសិនបើអ្នកបារម្ភពីរោគនេះ សូមនិយាយជាមួយវេជ្ជះបណ្ឌិតរបស់អ្នកភ្លាម។ ប្រសិនបើអ្នកឃើញមានស្ថានការណ៍ វិសកម្មភាពសង្ស័យនៅក្នុងសហគមន៍របស់អ្នក រួមទាំងការប្រើមេរោគជម្ងឺជាអាវុធនោះ សូមរាយការណ៍ទៅក្រសួងសមត្ថកិច្ចតំបន់របស់អ្នក។